# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## អនុស្សារណៈយោគយល់

រវាង

លេខាធិការដ្ឋាន គ.ជ.អ.ប

ជាមួយនិង

អង្គការទស្សនៈពិភពលោក

ស្តីពី

## ការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម
## សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# អនុស្សារណៈយោគយល់
# រវាង
# លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

# និង
# អង្គការទស្សនៈពិភពលោក
# ស្តីពីការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## ប្រការ១៖ គណនេយ្យភាពសង្គម

ផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី១(២០១៦-២០១៨) និងដំណាក់កាលទី ២ (២០១៩-២០២៣) បានរៀបចំឡើងដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធ រវាងលេខាធិការដ្ឋានគ.ជ.អ.ប និងបណ្តាអង្គការសង្គមស៊ីវិលពាក់ព័ន្ធ ក្រោមក្របខ័ណ្ឌកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការងារគណនេយ្យភាពសង្គមគឺជាផ្នែកមួយដ៏សំខាន់នៃអភិបាលកិច្ច និងជាដំណើរការនៃកាចូលរួមប្រកបដោយការស្តាបនារវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការធ្វើសេចក្តីសម្រេចចិត្តជាសាធារណៈ និងអនុវត្តសកម្មភាពនានា។ សកម្មភាពទាំងនោះរួមបញ្ចូលនូវសកម្មភាពដែលប្រជាពលរដ្ឋ និងតំណាងប្រជាពលរដ្ឋអាចធ្វើការផ្តល់យោបល់ត្រឡប់សម្រាប់ឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន និងអាចចូលរួមតាមដានត្រួតពិនិត្យ អំពីការអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សា មន្ត្រី និងអ្នកផ្តល់សេវាតាមរយៈ សេវារដ្ឋបាលឃុំ សេវាអប់រំ (សាលាបឋមសិក្សា) សេវាសុខាភិបាល (មណ្ឌលសុខភាព) សេវារដ្ឋបាលក្រុង ស្រុក ខណ្ឌ ក៏ដូចជាសេវាមួយចំនួនផ្សេងៗទៀត ស្របទៅតាមការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ប្រការ២៖ គោលបំណងនៃអនុស្សារណៈយោគយល់

អនុស្សារណៈយោគយល់នេះមានគោលបំណងកំណត់អំពីការទទួលខុសត្រូវ និងកិច្ចសហប្រតិបត្តិការរបស់ភាគីពីរគឺ លេខាធិការដ្ឋាន គ.ជ.អ.ប និងអង្គការទស្សនៈពិភពលោក សម្រាប់ការអនុវត្តសកម្មភាពផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ផ.អ.គ.ស) នៅក្នុងតំបន់គោលដៅ(ដូចមានក្នុងឧបសម្ព័នទី១) និងថវិកាគ្រោងប្រចាំឆ្នាំ (ដូចមានក្នុងឧបសម្ព័នទី២) ព្រមទាំងធ្វើបច្ចុប្បន្នភាពតំបន់គោលដៅអនុវត្ត និងថវិកា មួយឆ្នាំម្តងៗដោយពង្រីកវិសាលភាពតំបន់គោលដៅ និងវិសាលភាពសេវាគ្របដណ្តប់ ទៅតាមការព្រមព្រៀង និងធនធានថវិកាដែលមាន។

អនុស្សារណៈយោគយល់នេះនឹងមានសុពលភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅរហូតដល់ដំណាច់ឆ្នាំ២០២០។ អង្គការទស្សនៈពិភពលោកនឹងខិតខំប្រឹងប្រែងស្វែងរកការគាំទ្រថវិកា ដើម្បីអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គមនៅក្នុងតំបន់គោលដៅដែលបានគ្រោងក្នុងឧបសម្ព័ន្ធទី១ នឹងរំពឹងថានឹងមានការពង្រីកតំបន់គោលដៅថ្មី និងសេវាថ្មីៗបន្ថែមទៀត ស្របតាមផែនការអនុវត្តការងារងារគណនេយ្យភាពសង្គមដំណាក់កាលទី២(២០១៩-២០២៣)។

## ប្រការ៣៖ ការទទួលខុសត្រូវរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខាធិការដ្ឋាន គ.ជ.អ.ប.ព្រមព្រៀងដូចខាងក្រោម៖

១. ផ្តល់ការណែនាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងតំបន់គោលដៅ ស្តីពីខ្លឹមសារនៃអនុស្សារណៈយោគយល់នេះ។

២. ផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រីជំនាញវិស័យសុខាភិបាល និងមន្ត្រីជំនាញវិស័យអប់រំ (និងវិស័យផ្សេងៗទៀតតាមការកំណត់ជាក់ស្តែង)នៅក្នុងតំបន់គោលដៅ ទាក់ទងនឹងទស្សនៈទាន ឧបករណ៍ ដំណើរការនៃការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គម ជាពិសេសគោលការណ៍អភិបាលកិច្ច និងខ្សែគណនេយ្យភាព ព្រមទាំងតួនាទី ភារកិច្ចរបស់ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិលដែលចុះកិច្ចសន្យាអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គម និងអង្គការសង្គមស៊ីវិល (CSO) ដែលបានទទួលកិច្ចសន្យាបន្តពីអង្គការសង្គមស៊ីវិលដែលបានចុះកិច្ចសន្យាជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការលើកកម្ពស់គោលការណ៍ខាងលើ និងគាំទ្រសម្របសម្រួលការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គមនៅក្នុងតំបន់គោលដៅ។

៣. គាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋនៅតំបន់គោលដៅ ដោយប្រើផ្ទាំងរូបភាពធំនៃកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ(I4Cs) និងសៀវភៅណែនាំអំពីកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋដោយមានការណែនាំបច្ចេកទេស ឬតម្រង់ទិសពីរបៀបនៃការផលិតព័ត៌មាន ការដាក់តាំងបង្ហាញ ការផ្សព្វផ្សាយ និងរបៀបនៃការប្រើប្រាស់ព័ត៌មានទាំងនេះក្នុងដំណើរការ ផ.អ.គ.ស។

៤. សហការបណ្តុះបណ្តាលតម្រង់ទិស ដល់មន្ត្រីបង្គោលរបស់អង្គការដៃគូអនុវត្ត(NGOs) ស្តីពីផែនការអនុវត្តការងារគណនេយ្យភាពសង្គមដើម្បីអោយមានភាពស្របគ្នាជាមួយនឹងវគ្គបណ្តុះបណ្តាលបន្តរបស់ផ្នែកតម្រូវការដល់ដៃគូតាមបណ្តារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌគោលដៅ។

៥. ត្រួតពិនិត្យការអនុវត្តជាប្រចាំនូវការបំពេញការងារ ការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រីជំនាញផ្នែកសុខាភិបាល អប់រំ (និងវិស័យផ្សេងទៀតតាមការកំណត់ជាក់ស្តែង) ដែលពាក់ព័ន្ធដើម្បីធានាថាការផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ និងដំណើរការដាក់ពិន្ទុដោយផ្នែកទាំងពីរ (អង្គភាពផ្តល់សេវា និងប្រជាពលរដ្ឋ) ក្នុងដំណើរការអនុវត្ត ផ.អ.គ.ស ត្រូវបានអនុវត្តត្រឹមត្រូវ ពេញលេញ និងស្របតាមវដ្តនៃសកម្មភាពការអនុវត្តផែនការគណនេយ្យភាពសង្គមប្រចាំឆ្នាំ និងសៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការការងារគណនេយ្យភាពសង្គមរបស់ផ្នែកផ្គត់ផ្គង់។

៦. រៀបចំ និងចែករំលែកនូវរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តជាទៀងទាត់ដូចដែលបានឯកភាពគ្នាតាមមាតិកានៃរបាយការណ៍ដែលមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី៣។

៧. សម្របសម្រួល និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ផ្នែកផ្គត់ផ្គង់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងដំណើរការអនុវត្តការងារគណនេយ្យភាពសង្គមប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ពីមួយឆ្នាំទៅមួយឆ្នាំនៅក្នុងតំបន់គោលដៅដែលបានកំណត់។

## ប្រការ៤៖ ការទទួលខុសត្រូវរបស់អង្គការទស្សនៈពិភពលោក

អង្គការទស្សនៈពិភពលោក ព្រមព្រៀងដូចខាងក្រោម៖

១. ផ្តល់ការណែនាំដល់បុគ្គលិក និងអង្គការសង្គមស៊ីវិលដៃគូអនុវត្តរបស់ខ្លួនទាក់ទងនឹងខ្លឹមសារ នៃអនុស្សារណៈនេះ។

២. ធានាថាការបណ្តុះបណ្តាលត្រូវបានផ្តល់ដល់ដៃគូអង្គការសង្គមស៊ីវិលដែលជាដៃគូអនុវត្តរបស់ខ្លួនអំពីទស្សនៈទាន ឧបករណ៍នីតិវិធីដំណើរការ គោលការណ៍អភិបាលកិច្ចល្អ ខ្សែគណនេយ្យភាព សារៈសំខាន់នៃ ការចូលរួមរបស់ប្រជាពលរដ្ឋ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋក្នុងការអនុវត្ត ផ.អ.គ.ស។

៣. ផ្តល់ថវិកាគាំទ្រអោយទាន់ពេលវេលាដល់អង្គការសង្គមស៊ីវិល ដែលជាដៃគូរបស់ខ្លួនដើម្បីគាំទ្រការអនុវត្តសកម្មភាពផ្នែកគម្រូវការក្រោមការទទួលខុសត្រូវរបស់អង្គការដៃគូនោះ។

៤. ត្រួតពិនិត្យការអនុវត្តជាប្រចាំរបស់ខ្លួន ឬអង្គការសង្គមស៊ីវិលដែលជាដៃគូអនុវត្តរបស់ខ្លួន ដើម្បីធានាថា ផ.អ.គ.ស ត្រូវបានអនុវត្តត្រឹមត្រូវពេញលេញដោយមានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្របតាមឯកសារផែនការអនុវត្តការងារគណនេយ្យភាពសង្គម និងសៀវភៅណែនាំ ស្តីពីកិច្ចប្រតិបត្តិការការងារគណនេយ្យភាពសង្គមរបស់ផ្នែកគម្រូវការ។

៥. រៀបចំ និងចែករំលែកនូវរបាយការណ៍ស្តីពី វឌ្ឍនភាពនៃការអនុវត្តជាទៀងទាត់ ដូចដែលបានឯកភាពគ្នាតាមមាតិកានៃរបាយការណ៍ដែលមានភ្ជាប់ជូនជូនក្នុងឧបសម្ព័ន្ធទី ៣។

៦. សហការយ៉ាងជិតស្និទ្ធជាមួយផ្នែកផ្គត់ផ្គង់ ទាំងនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងដំណើរការអនុវត្តការងារគណនេយ្យភាពសង្គមប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ពីមួយឆ្នាំទៅមួយឆ្នាំនៅក្នុងតំបន់គោលដៅដែលបានកំណត់។

## ប្រការ៥៖ ការចាត់ចែងសម្របសម្រួល

ក្នុងករណីចាំបាច់ ភាគីទាំងពីរអាចរៀបចំប្រជុំសម្របសម្រួលលើដំណើរការអនុវត្តគណនេយ្យភាពសង្គមជាប្រចាំ ក្នុងគោលបំណងដូចខាងក្រោម៖

- ពិនិត្យមើលអំពីភាពរីកចម្រើននៃការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គម
- កំណត់ពីបញ្ហា និងស្វែងរកដំណោះស្រាយប្រកបដោយការសហការគ្នា
- ពិភាក្សានិងព្រមព្រៀងលើចំណុចកែលម្អក្នុងដំណើរការអនុវត្តដែលបានលើកឡើង ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអនុវត្តនាពេលអនាគត។
- ការងារផ្សេងៗទៀតទាក់ទងនឹងការអនុវត្តផែនការគណនេយ្យភាពសង្គមជាទូទៅ

## ប្រការ៦៖  ការធ្វើវិសោធនកម្ម ឬការបញ្ចប់អនុស្សារណៈយោគយល់

អនុស្សារណៈយោគយល់នេះ  អាចនឹងត្រូវបានធ្វើវិសោធនកម្មនៅពេលណាមួយក្នុងករណីដែលមានការព្រមព្រៀងពីភាគីទាំងពីរ។  ការបញ្ចប់អនុស្សារណៈនេះ  នឹងតម្រូវអោយមានការជូនដំណឹងជាលាយលក្ខណ៍អក្សរយ៉ាងតិច៨សប្តាហ៍មុន និងមានការព្រមព្រៀងពីភាគីទាំងពីរទៅលើវិធានការសមស្របដើម្បីធានាឲ ឱ្យមានការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមនៅក្នុងតំបន់គោលដៅបន្ទាប់ពីការបញ្ចប់អនុស្សារណៈយោគយល់នេះ។

| | **លេខាធិការដ្ឋាន គ.ជ.អ.ប** | **អង្គការទស្សនៈពិភពលោក** |
|---|---|---|
| ហត្ថលេខា៖ | | |
| ឈ្មោះ៖ | ចាន់ បំរើន | Robert ... |
| មុខងារ៖ | ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប | INTERIM NATIONAL DIRECTOR |
| កាលបរិច្ឆេទ៖ | 24.05.2019 | 24.05.2019 |

ឧបសម្ព័ន្ធទី១៖

**តំបន់គោលដៅសម្រាប់អនុវត្តឆ្នាំ ២០១៩ ដល់ ២០២០ ដែលកំណត់ក្នុងអនុស្សារណៈរវាងលេខាធិការដ្ឋានគ.ជ.អ.ប និងអង្គការទស្សនៈពិភពលោក**

| ល.រ | ឈ្មោះខេត្ត | ឈ្មោះស្រុក | ឃុំ | | សាលាបឋមសិក្សា | | មណ្ឌលសុខភាព | | ប្រភពថវិកា |
|---|---|---|---|---|---|---|---|---|---|
| | | | ចំនួនឃុំសរុប | ចំនួនឃុំអនុវត្ត | ចំនួនសាលាសរុប | ចំនួនសាលាអនុវត្ត | ចំនួនមណ្ឌលសុខភាព | ចំនួនមណ្ឌលសុខភាព | |
| ១ | កំពង់ចាម | កងមាស | 11 | 11 | 43 | 22 | 8 | 8 | សហគមន៍អឺរ៉ុប |
| | | កោះសូទិន | 8 | 8 | 33 | 16 | 7 | 7 | |
| | | កំពង់សៀម | 15 | 15 | 49 | 28 | 11 | 11 | |
| | | ចំការលើ | 8 | 8 | 44 | 16 | 8 | 8 | |
| | | ជើងព្រៃ | 10 | 10 | 37 | 20 | 6 | 6 | |
| | | បាធាយ | 12 | 12 | 45 | 24 | 8 | 8 | |
| | | ព្រៃឈរ | 15 | 15 | 59 | 28 | 11 | 11 | |
| | | ស្ទឹងត្រង់ | 12 | 12 | 47 | 21 | 11 | 11 | |
| **កំពង់ចាម សរុប** | | **8** | **91** | **91** | **357** | **175** | **70** | **70** | |
| ២ | កំពង់ស្ពឺ | ថ្ពង | 7 | 7 | 26 | 14 | 4 | 4 | សហគមន៍អឺរ៉ុប |
| | | ភ្នំស្រួច | 12 | 12 | 52 | 22 | 6 | 6 | |
| | | សំរោងទង | 15 | 15 | 52 | 29 | 9 | 9 | |
| **កំពង់ស្ពឺ សរុប** | | **3** | **34** | **34** | **130** | **65** | **19** | **19** | |
| | | កោះអណ្តែត | 6 | 6 | 19 | 11 | 5 | 5 | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣ | តាកែវ | គិរីវង់ | 12 | 12 | 56 | 24 | 11 | 11 | សហគមន៍អ៊ឺរ៉ុប |
| | | ត្រាំកក់ | 15 | 15 | 65 | 30 | 13 | 13 | |
| | | ទ្រាំង | 14 | 14 | 53 | 28 | 10 | 10 | |
| | | បាទី | 15 | 15 | 50 | 30 | 10 | 10 | |
| | | បូរីជលសារ | 5 | 5 | 19 | 10 | 4 | 4 | |
| | | ព្រៃកប្បាស | 13 | 13 | 40 | 26 | 8 | 8 | |
| | | សំរោង | 11 | 11 | 47 | 22 | 8 | 8 | |
| | | អង្គរបូរី | 6 | 6 | 19 | 12 | 4 | 4 | |
| | **តាកែវ សរុប** | **9** | **97** | **97** | **368** | **193** | **73** | **73** | |
| ៤ | បាត់ដំបង | គាស់ក្រឡ | 6 | 6 | 38 | 12 | 2 | 2 | សហគមន៍អ៊ឺរ៉ុប |
| | | បាណន់ | 8 | 8 | 65 | 16 | 6 | 6 | |
| | | ភ្នំព្រឹក | 5 | 5 | 34 | 10 | 4 | 4 | |
| | | មោងឫស្សី | 9 | 9 | 68 | 18 | 9 | 9 | |
| | | រតនមណ្ឌល | 5 | 5 | 35 | 10 | 3 | 3 | |
| | | រុក្ខគិរី | 5 | 5 | 32 | 10 | 2 | 2 | |
| | **បាត់ដំបង សរុប** | **6** | **38** | **38** | **272** | **76** | **26** | **26** | |
| ៥ | ពោធិ៍សាត់ | កណ្ដៀង | 9 | 9 | 42 | 16 | 7 | 7 | សហគមន៍អ៊ឺរ៉ុប |
| | | ក្រគរ | 11 | 11 | 60 | 22 | 9 | 9 | |
| | | ភ្នំក្រវាញ | 7 | 7 | 53 | 14 | 5 | 5 | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | **ពោធិ៍សាត់ សរុប** | **3** | **27** | **27** | **155** | **52** | **21** | **21** | |
| ៦ | កំពង់ឆ្នាំង | កំពង់ត្រឡាច | 10 | 10 | 48 | 20 | 7 | 7 | ធនាគារពិភពលោក និង អង្គការទស្សន ពិភពលោក |
| | | កំពង់លែង | 9 | 9 | 30 | 17 | 4 | 4 | |
| | | បរិបូណ៌ | 11 | 11 | 30 | 21 | 5 | 5 | |
| | | រលាប្អៀរ | 13 | 13 | 59 | 26 | 9 | 9 | |
| | **កំពង់ឆ្នាំង សរុប** | **4** | **43** | **43** | **167** | **84** | **25** | **25** | |
| ៧ | កំពង់ធំ | កំពង់ស្វាយ | 11 | 11 | 75 | 22 | 8 | 8 | ធនាគារពិភពលោក និង អង្គការទស្សន ពិភពលោក |
| | | បារាយណ៍ | 18 | 18 | 89 | 36 | 16 | 16 | |
| | | ប្រាសាទបល្ល័ង្គ | 7 | 7 | 44 | 14 | 3 | 3 | |
| | | សណ្ដាន់ | 9 | 9 | 55 | 18 | 3 | 3 | |
| | | សន្ទុក | 10 | 10 | 66 | 20 | 7 | 7 | |
| | | ស្ទោង | 13 | 13 | 80 | 26 | 8 | 8 | |
| | **កំពង់ធំ សរុប** | **6** | **68** | **68** | **409** | **136** | **45** | **45** | |
| ៨ | បន្ទាយមានជ័យ | ថ្មពួក | 6 | 6 | 44 | 12 | 6 | 6 | ធនាគារពិភពលោក និង អង្គការទស្សន ពិភពលោក |
| | | ភ្នំស្រុក | 6 | 6 | 41 | 12 | 6 | 6 | |
| | | មង្គលបូរី | 13 | 13 | 73 | 26 | 14 | 14 | |
| | | ស្វាយចេក | 8 | 8 | 44 | 14 | 7 | 7 | |
| | **បន្ទាយមានជ័យ សរុប** | **4** | **33** | **33** | **202** | **64** | **33** | **33** | |
| ៩ | ព្រះវិហារ | គូលែន | 6 | 6 | 32 | 12 | 4 | 4 | ធនាគារពិភពលោក |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ឆែប | 8 | 8 | 25 | 16 | 3 | 3 | និង<br>អង្គការទស្សន<br>ពិភពលោក |
| | | ជាំក្សាន្ត | 8 | 8 | 45 | 16 | 7 | 7 | |
| | | ជ័យសែន | 6 | 6 | 21 | 11 | 3 | 3 | |
| | | ត្បែងមានជ័យ | 4 | 4 | 9 | 7 | 0 | 0 | |
| | | រវៀង | 12 | 12 | 51 | 24 | 3 | 3 | |
| | | សង្គមថ្មី | 5 | 5 | 23 | 10 | 1 | 1 | |
| | **ព្រះវិហារ សរុប** | **7** | **49** | **49** | **206** | **96** | **21** | **21** | |
| ១០ | សៀមរាប | ក្រឡាញ់ | 10 | 10 | 37 | 19 | 9 | 9 | ធនាគារពិភពលោក<br>និង<br>អង្គការទស្សន<br>ពិភពលោក |
| | | ជីក្រែង | 12 | 12 | 75 | 24 | 12 | 12 | |
| | | វ៉ារិន | 5 | 5 | 24 | 10 | 4 | 4 | |
| | **សៀមរាបសរុប** | **3** | **27** | **27** | **136** | **53** | **25** | **25** | |
| | **សរុបរួម** | **53** | 507 | 507 | 2402 | 994 | 358 | 358 | |

*<u>បញ្ជាក់៖</u> តំបន់គោលដៅសម្រាប់អនុវត្តឆ្នាំ ២០១៩ និង ២០២០ ខាងលើអាចនឹងមានការផ្លាស់ប្តូរក្នុងករណីចាំបាច់ ដោយស្របតាមការពិភាក្សា និងឯកភាពរវាងភាគីទាំងពីរ*

ឧបសម្ព័ន្ធទី២៖

## ថវិកាគ្រោងសម្រាប់អនុវត្តប្រចាំឆ្នាំ ២០១៩ ដល់ ២០២០ ដែលកំណត់ក្នុងអនុស្សារណៈរវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងអង្គការទស្សនៈពិភពលោក

| ល.រ | សមាសភាគ | ឆ្នាំ ២០១៩ (ដុល្លារ) | ឆ្នាំ២០២០(ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|
| ១ | សមាសភាគទី១៖ តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា | 240,644.98 | 213,959.98 | EU/WB/WVI |
| ២ | សមាសភាគទី២៖ ការត្រួតពិនិត្យ តាមដានដោយប្រជាពលរដ្ឋ | 303,951.66 | 236,799.66 | EU/WB/WVI |
| ៣ | សមាសភាគទី៣៖ ការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម | 248,786.80 | 219,662.80 | EU/WB/WVI |
| ៤ | សមាសភាគទី ៤ ៖ ការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាព និងការទំនាក់ទំនង | 124,172.54 | 118,772.54 | EU/WB/WVI |
| ៥ | សមាសភាគទី ៥ ៖ ការគ្រប់គ្រង ត្រួតពិនិត្យតាមដាន និងវាយតម្លៃ | 415,825.57 | 413,233.57 | EU/WB/WVI |
| ៦ | ផ្សេងៗ | | | |
| | **ថវិកាគ្រោងសរុប** | 1,333,381.55 | 1,202,428.55 | |

*<u>បញ្ជាក់</u>៖ ថវិកាគ្រោងប្រចាំឆ្នាំសម្រាប់អនុវត្តឆ្នាំ ២០១៩ និង ២០២០ ខាងលើអាចនឹងមានការផ្លាស់ប្តូរក្នុងករណីចាំបាច់ ដោយស្របតាមការពិភាក្សា និងឯកភាពរវាងភាគីទាំងពីរ*

**ឧបសម្ព័ន្ធទី៣៖**

**ទម្រង់មាតិកានៃរបាយការណ៍ប្រចាំត្រីមាសស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម**

**១. សេចក្តីផ្តើម**

**២. វឌ្ឍនៈភាពនៃការអនុវត្ត**

**៣. បញ្ហាប្រឈម**

**៤ ស្ថានភាពហិរញ្ញវត្ថុ**

**៥. សេចក្តីសន្និដ្ឋាន**